ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦

## សេចក្ដីសង្ខេបព័ត៌មានប្រចាំថ្ងៃដោយការិយាល័យអ្នកនាំពាក្យអគ្គលេខាធិការ

សេចក្ដីសង្ខេបព័ត៌មានថ្ងៃត្រង់ ដោយ ស្ដេហ្វាន់ ដ្យូហ្សារិក (Stéphane Dujarric) អ្នកនាំពាក្យអគ្គលេខាធិការ

សំណួរៈ ប្រាកដណាស់។ ខ្ញុំចង់សួរថា នៅក្នុងប្រទេសកម្ពុជា អ្នកធ្វើយុទ្ធនាការសិទ្ធិមនុស្សរូបនេះ គឺ លោក កែម ឡី ត្រូវបានគេសម្លាប់។ មានអ្នករាយការណ៍ពិសេសមួយរូបក្នុងចំណោមអ្នករាយការណ៍ពិសេសផ្សេងទៀង បាននិយាយលើកឡើងពីបញ្ហានេះ ប៉ុន្តែគណបក្សប្រឆាំងពិតជាបានស្នើសុំឲ្យមានការចូលរួមរបស់អ.ស.ប ក្នុងការស៊ើបអង្កេតលើការសម្លាប់ លោក កែម ឡី ដែលជាអ្នករិះគន់ខ្លាំងៗលើ លោក ហ៊ុន សែន ហើយតើ អ.ស.ប បានដឹងអំពីសំណើសុំនោះដែរឬទេ? តើពួកគេនឹង ...?

អ្នកនាំពាក្យៈ ទេ មិនបានដឹងទេ។ ខ្ញុំមិនបានឃើញសំណើនេះទេ។ ជាការពិតណាស់ ខ្ញុំគិតថាលោកអគ្គលេខាធិការមានមានការក្រៀមក្រំណាស់បន្ទាប់ពីបានឮដំណឹងពីការស្លាប់របស់លោក កែម ឡី។ យើងសង្ឃឹមថាអាជ្ញាធរនឹងធ្វើការស៊ើបអង្កេតពេញលេញ និងមិនលំអៀងលើករណីរបស់គាត់ ... ការបាញ់ប្រហារការស្លាប់របស់គាត់។ ខ្ញុំគិតថា ជារួម លោកអគ្គលេខាធិការនៅតែមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីស្ថានភាពនៅក្នុងប្រទេសកម្ពុជា រាប់ទាំង របាយការណ៍នៃការបំភិតបំភ័យជាទូទៅ, ការយាយី និងការចាប់ខ្លួនសមាជិកនៃសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ សមាជិកនៃគណបក្សប្រឆាំង និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ លោកអំពាវនាវឲ្យមានការគោរពពេញលេញនូវសិទ្ធិមនុស្ស រាប់ទាំងសេរីភាពនៃការសម្ដែងមតិ សេរីភាពបង្កើតសមាគម និងសេរីភាពក្នុងការជួបប្រជុំ។